ដំណើររឿងប្រព័ន្ធផ្សព្វផ្សាយ
ដើម្បីផ្លាស់ប្តូរការរើសអើង
ប្រកាន់ភេទនិងគំរូភេទ



# ប្អូនចង់បានទៅសាលា

(Em muốn được tới trường)

*កុមារានិងកុមារីសុទ្ធតែមានសិទ្ធិបានទៅរៀន*

Hoàng Đức & Edlab

BÌNH ĐẲNG GIỚI
VÙNG DÂN TỘC THIỂU SỐ & MIỀN NÚI
CHƯƠNG TRÌNH MỤC TIÊU QUỐC GIA DTTS & MN

NHÀ XUẤT BẢN
PHỤ NỮ VIỆT NAM




# ប្អូនចង់បានទៅសាលា

*កុមារានិងកុមារីសុទ្ធតែមានសិទ្ធិបានទៅរៀន*

**Hoàng Đức & Edlab**

អ្នកបកប្រែ៖ **Kiêm Hạnh**

NHÀ XUẤT BẢN PHỤ NỮ VIỆT NAM

# អារម្ភកថា

កម្មវិធីគោលដៅជាតិអភិវឌ្ឍសេដ្ឋកិច្ច – សង្គមកិច្ចតំបន់ជនជាតិភាគតិចនិងតំបន់ភ្នំ ដែលបានអនុម័តដោយនាយករដ្ឋមន្ត្រីតាមសេចក្តីសម្រេចលេខ១៧១៩/QĐ-TTg ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២២ មានសរុប១០គម្រោងសមាសភាព។ ក្នុងនោះ សមាគមសម្ព័ន្ធនារីវៀតណាមដឹកនាំគម្រោងទី៨៖ *“អនុវត្តសមភាពភេទនៅតំបន់ជនជាតិភាគតិចនិងតំបន់ភ្នំ”*។

ដោយមានគោលបំណង “បង្កើនការយល់ដឹង ផ្លាស់ប្តូរការរើសអើងប្រកាន់ភេទ ថែរក្សានិងដោះស្រាយបញ្ហាបន្ទាន់សម្រាប់ស្ត្រីនិងកុមារ”។ គម្រោងទី៨នេះរួមមាន៤ខ្លឹមសារ ជ្រៀតជ្រែកជាមួយសកម្មភាពចម្បង៖

- ផ្សព្វផ្សាយ ឃោសនាផ្លាស់ប្តូរ “ផ្នត់គំនិត របៀបធ្វើ” រួមចំណែកការលុបចោលបណ្តាការរើសអើងប្រកាន់ភេទនិងគំរូភេទក្នុងគ្រួសារនិងសហគមន៍ ជាមួយនឹងទំនៀមទម្លាប់អាក្រក់និងបញ្ហាសង្គមបន្ទាន់សម្រាប់ស្ត្រីនិងកុមារ។
- កសាងនិងពង្រីកបណ្តាគំរូផ្លាស់ប្តូរ “ផ្នត់គំនិត របៀបធ្វើ” លើកកម្ពស់អំណាចសេដ្ឋកិច្ចសម្រាប់ស្ត្រីនិងជំរុញសមភាពភេទ និងដោះស្រាយបញ្ហាបន្ទាន់សម្រាប់ស្ត្រីនិងកុមារ។
- ធានាសិទ្ធិឱ្យស្ត្រីនិងកុមារមានសិទ្ធិនិយាយ និងចូលរួមយ៉ាងពិសេសក្នុងសកម្មភាពអភិវឌ្ឍសេដ្ឋកិច្ច – សង្គមកិច្ចរបស់សហគមន៍ ត្រួតពិនិត្យនិងការផ្តល់យោបល់ជំនួយស្ត្រីចូលរួមគ្រប់គ្រងដឹកនាំក្នុងប្រព័ន្ធនយោបាយ។
- ផ្តល់ចំណេះដឹងអំពីសមភាពភេទ និងបំណិននៃការអនុវត្តដាក់បញ្ចូលភេទសម្រាប់កម្មាភិបាលមេភូមិ អ្នកមុខអ្នកការសាសនា និងអ្នកមានប្រជាប្រិយភាពនៅក្នុងសហគមន៍។

កម្រងសៀវភៅ *"ដំណើររឿងផ្សព្វផ្សាយផ្លាស់ប្តូរការរើសអើងប្រកាន់ភេទនិងគំរូភេទ"* ដែលជាផ្នែកមួយនៃគម្រោងទី៨ ត្រូវបានគ្រឹះស្ថានបោះពុម្ពផ្សាយនារីវៀតណាមចាត់តាំង រួមមានចំនួន៤ក្បាល ដែលត្រូវបានសរសេរជាប្រភេទរឿងងាយស្រួលយល់ និងជិតស្និទ្ធជាមួយបណ្តាជនជាតិភាគតិចៈ

១. ***កិច្ចការផ្ទះជាការងាររួម*** – រួមគ្នាចែករំលែក រួមគ្នាជឿនលឿន រួមសុភមង្គល។

២. ***ប្អូនចង់បានទៅសាលា*** – កុមារានិងកុមារីសុទ្ធតែមានសិទ្ធិបានទៅរៀន។

៣. ***ផ្ទះពីរដំបូល*** – ស្ត្រីអាចធ្វើសេដ្ឋកិច្ច រួមកសាងគ្រួសារសុខដុមរមនា ជឿនលឿនសុភមង្គល។

៤. ***ការពិតយើងក៏អាចធ្វើបានដែរ*** – មនុស្សគ្រប់គ្នាសុទ្ធតែមានសក្តានុពល ភាពខ្លាំងដើម្បីសិក្សា ជោគជ័យនិងសុភមង្គល។

នេះជាកម្រងសៀវភៅសម្រាប់ជំនួយស្ត្រីនិងកុមារ កម្មាភិបាលនៅមូលដ្ឋាននិយាយរួម ក្នុងនោះមានកម្មាភិបាលសមាគមនារី បានផ្សព្វផ្សាយដ៏ល្អបណ្តាខ្លឹមសារឃោសនា "អនុវត្តសមភាពភេទនៅតំបន់ជនជាតិភាគតិចនិងតំបន់ភ្នំ"។

សង្ឃឹមថាកម្រងសៀវភៅនេះអាចនឹងរួមចំណែកផ្លាស់ប្តូរនូវទំនៀមទម្លាប់ហួសសម័យ ទំនៀមទម្លាប់ឱនថយ។ ទន្ទឹមនោះ លើកទឹកចិត្ត ពង្រីកនូវតម្លៃជឿនលឿនសម្រាប់ឱ្យស្ត្រីនិងកុមារនៅតំបន់ជនជាតិភាគតិចនិងតំបន់ភ្នំ។

សូមឧទ្ទេសនាមជូនមិត្តអ្នកអាន។

**គ្រឹះស្ថានបោះពុម្ពផ្សាយនារីវៀតណាម**



*★ កំណត់សម្គាល់៖ រូបភាពសំលៀកបំពាក់នៅក្នុងសៀវភៅគ្រាន់តែមានលក្ខណៈជាតួសម្តែងប៉ុណ្ណោះ។*



តាំងពីបុរាណមក មនុស្សបានរក្សាទុក
នូវការសង្កេតមើលអំពីធម្មជាតិ
និងមនុស្សលោក...



... និងរួមទាំងដំណើររឿង និងក្ដីសុបិន
របស់ខ្លួនតាមរយៈស្នាមគំនូរនៅលើ
ជញ្ជាំងរូងភ្នំ។



បន្ទាប់មក មនុស្សបានបង្កើតអក្សរ
ហើយចាប់ផ្ដើមកត់ត្រា...





... នៅលើស្មោកអណ្ដើក ឆ្អឹងសត្វ ថ្ម និងលោហៈ។
ប៉ុន្តែ ការកត់ត្រានិងការអាននៅតែ
មានការលំបាក!

បន្ទាប់មក គេចាប់ផ្ដើមឆ្លាក់អក្សរ។
ពួកគេឆ្លាក់លើបន្ទះឫស្សី ឬសរសេរលើស្បែកសត្វ។
ប៉ុន្តែ ការអានសៀវភៅនៅតែមានផលប្រយោជន៍ចំពោះ
មនុស្សមួយចំនួនតិច ដោយសាសៀវភៅឫស្សី សៀវភៅ
ស្បែកសត្វមានតម្លៃខ្ពស់ពេក។





ហើយបន្ទាប់មក គេបានបង្កើតថ្មីក្រដាស!



ដោយសារតែការផលិតនិងដឹកជញ្ជូន
យ៉ាងងាយស្រួល ទើបការប្រើប្រាស់
ក្រដាសបានក្លាយជាការពេញនិយម។



ដោយសារតែមានក្រដាស និងបច្ចេកវិទ្យាបោះពុម្ព
នៅក្រោយមកនេះ សៀវភៅត្រូវបានផលិតកាន់តែច្រើន
និងចំណេះវិជ្ជារបស់មនុស្សលោកត្រូវបាន
ផ្សព្វផ្សាយទូលំទូលាយ។







ចំណេះវិជ្ជាត្រូវបានផ្សព្វផ្សាយ ដែល
ជំនួយឱ្យប្រទេសក្រីក្រក៏អាចអភិវឌ្ឍ
សេដ្ឋកិច្ច – សង្គមកិច្ចបន្តិចម្តងៗ។



ប៉ុន្តែ ក៏មិនមែនក្រដាសប្រភេទណា...



... ជួនកាលក៏មានក្ដីសប្បាយរីករាយពេល
ដែលបានចែករំលែកចំណេះវិជ្ជាដូច្នេះ។



ក៏ដូចជាដំណើររឿងនៃទំព័រក្រដាសពណ៌ផ្កាឈូក ក៏មានកុមារខ្លះមិនទទួលបានសេចក្តីសប្បាយរីករាយនៃការចែករំលែកចំណេះវិជ្ជាដែរ ពីព្រោះពួកគេមិនមានឱកាសទៅសាលានិងជ្រើសរើសការងារដែលខ្លួនស្រឡាញ់បានឡើយ...





ប៉ុន្តែ ការពិត៖ ក្រដាសពណ៌ផ្កាឈូកអាចប្រើធ្វើវិក្កយបត្រ
គិតលុយបាន។




ក់ទំនិញ
0062215

ក្រដាសពណ៌ផ្កាឈូកក៏អាចបោះពុម្ព
ជាសៀវភៅកំណត់ត្រាជំងឺផងដែរ...



... ជំនួយលោកគ្រូពេទ្យតាមដាន
សុខភាពរបស់អ្នកជំងឺ។





“ រៀនត្រូវដើរទន្ទឹមជាមួយនឹងអនុវត្ត
អនុវត្តផង រៀនផង ទើបក្លាយទៅជាអ្នកវៃឆ្លាត។ ”

– សុភាសិតជនជាតិគិញ

នៅមានសៀវភៅជាច្រើនក្បាល
ដែលមានពណ៌ផ្កាឈូក!



និងមានសំបុត្រតែមនិងប្រៃសណីយ៍បត្រពណ៌ផ្កាឈូក
ជាច្រើន ដែលជួយឱ្យយើងអាចផ្ញើអំណោយ
និងលិខិតទៅកាន់គ្រប់ទីកន្លែងបាន។





យើងមិនគួរគិតថា ក្រដាសពណ៌ផ្កាឈូក
សម្រាប់ទុកតែធ្វើផ្កាឬសម្រាប់ទុកវេចកាដូ។



ក៏ដូចជា យើងក៏មិនគួរតែគិតថា កូនស្រីគួរធ្វើតែ
ការងារផ្ទះ ឬដេរសម្លៀកបំពាក់ទេ។
កូនស្រីអាចធ្វើបានច្រើនវិស័យផ្សេងៗ។





កុមារានិងកុមារី មានសិទ្ធិស្មើគ្នា
ក្នុងការសិក្សារៀនបង្កើតគុណធម៌និងរៀនវិជ្ជាជីវៈដូចគ្នា!



អនុវត្តតាមច្បាប់សមភាពភេទឆ្នាំ២០០២៖

- ប្រុសនិងស្រីមានសិទ្ធិស្មើគ្នានៅក្នុងវ័យទៅរៀន បណ្តុះបណ្តាលនិងបំប៉ន។
- ប្រុសនិងស្រីមានសិទ្ធិស្មើគ្នាក្នុងការជ្រើសរើសវិស័យសិក្សានិងការបណ្តុះបណ្តាល។

*“ ឃ្លោកត្រឡាចក៏មានបណ្តូល*
*មនុស្សអ្នកណាក៏មានប្រាជ្ញាដូចគ្នា។ ”*

*– សុភាសិតជនជាតិខ្មែរ*



កុមារានិងកុមារី សុទ្ធតែមានសិទ្ធិបានទៅរៀន
និងទទួលបានសមភាពឈានទៅដល់ចំណេះវិជ្ជា
ក៏ដូចជាបណ្តាគោលនយោបាយអំពីអប់រំ។





ពួកប្អូន
ចង់បានទៅសាលា!

*Chịu trách nhiệm xuất bản:*
Giám đốc - Tổng biên tập
**Khúc Thị Hoa Phượng**

| | |
|---|---|
| Biên tập: | Nguyễn Thị Hòa Bình |
| | Vũ Thị Phương |
| Bìa: | Lộc Linh |
| Trình bày: | Lộc Linh - Xuân Ngân |
| Sửa bản in: | Anh Đào |

**NHÀ XUẤT BẢN PHỤ NỮ VIỆT NAM**
39 Hàng Chuối - Hà Nội
ĐT: (024) 39717979 - 39717980 - 39716727 - 39712832
Fax: (024) 39712830
E-mai: nxbphunu.com.vn
Website: www.nxbphunu.com.vn

Chi nhánh:
16 Alexandre de Rhodes - Q1 - TP. Hồ Chí Minh
ĐT: (028) 38234806

---

**ប្អូនចង់បានទៅសាលា**

(EM MUỐN ĐƯỢC TỚI TRƯỜNG) - TIẾNG KHMER